ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ៩៥៦ ៧៧ /គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦

**គោរពជូន**

**ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត**

**ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ**

**កម្មវត្ថុ** ៖សំណើកែលម្អឡើងវិញនូវគុណភាពគម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំ សង្កាត់ ដែលស្ថិតក្នុងរយៈពេលធានា ក្នុងក្របខ័ណ្ឌគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប (TSSD) ។

**យោង** ៖របាយការណ៍ពិនិត្យមើលលទ្ធផលនៃការអនុវត្តគម្រោង TSSD របស់ក្រុមបេសកកម្មធនាគារអភិវឌ្ឍន៍អាស៊ី ថ្ងៃទី៧-៣១ តុលា ២០១៦ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលដោយបានទទួលជំនួយគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ីតាមរយៈគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប បានផ្តល់មូលនិធិបន្ថែមដល់១៩៦ឃុំ សង្កាត់គោលដៅក្នុងខេត្តចំនួនប្រាំ (កំពង់ចាម ត្បូងឃ្មុំ កំពង់ធំ សៀមរាប និងបន្ទាយមានជ័យ) ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការបង្កើនផលិតភាពកសិកម្ម ដែលបានលើកឡើងនៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ (CIP) ។ ក្នុងអំឡុងពេលចុះពិនិត្យមើលការអនុវត្តគម្រោងនៅតាមខេត្តគោលដៅគម្រោង ក្រុមបេសកកម្មបានរកឃើញថា ការសិក្សា គុណភាពសាងសង់ ព្រមទាំងការប្រើប្រាស់ និងថែទាំគម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំមួយចំនួននៅមានការខ្វះចន្លោះច្រើន និងមានគុណភាពមិនតាមស្តង់ដាលក្ខណៈបច្ចេកទេស ដែលគម្រោងទាំងនោះសាងសង់មិនបានចប់ពេញលេញ ដែលត្រូវការសំណង់បន្ថែមមួយចំនួនទៀតដូចជា លូ ទ្វារទឹក ជាដើម ដើម្បីឱ្យប្រើប្រាស់បាន ដូចជាករណីមួយនៃគម្រោងធារាសាស្ត្រ មានទឹកហូរលើខ្នងប្រឡាយ ។ ម្យ៉ាងទៀត ផ្លូវលំមួយខ្សែមានប្រវែងសរុប ២០០០ម៉ែត្រ សាងសង់បានតែ១៧៥០ម៉ែត្រ ដោយសារទំហំថវិកាឃុំមានកម្រិត ប៉ុន្តែបើផ្នែកដែលនៅសល់បានសាងសង់ក្នុងពេលតែមួយនោះ ផ្លូវនេះនឹងបានប្រើប្រាស់ពេញលេញ ។ ផ្លូវមួយខ្សែទៀតក៏បានរកឃើញថា ការសាងសង់មានគុណភាពល្អតែត្រូវបានជីកកាត់ដាក់លូរំដោះទឹកជំនន់តាមក្រោយ ដែលនាំឱ្យផ្លូវនេះខកខានមិនបានប្រើប្រាស់មួយរយៈ បញ្ហាដាក់លូនេះវាគួរតែមានពេលសិក្សាលក្ខណៈបច្ចេកទេសពីដំបូង ។

អាស្រ័យហេតុនេះ សូមឯកឧត្តម ណែនាំដល់មន្ត្រីពាក់ព័ន្ធទាំងអស់ ជាពិសេសគណៈកម្មការគ្រប់គ្រងគម្រោងឃុំ សង្កាត់ ឱ្យយកចិត្តទុកដាក់តាមដានត្រួតពិនិត្យគុណភាពសំណង់ និងស្នើឱ្យអ្នកទទួលការជួសជុលកែលម្អឡើងវិញនូវគម្រោងទាំងឡាយណាដែលស្ថិតក្នុងរយៈពេលធានា៦ខែ ដើម្បីធានាបានការប្រើប្រាស់ និងមានការថែទាំប្រកបដោយប្រសិទ្ធភាព ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**ជ. ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

<u>ចម្លងជូន៖</u>

- ធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា
  «ដើម្បីជូនជ្រាប»
- ឯកសារ-កាលប្បវត្តិ